វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រសួងកសិកម្ម

ប្រកាស/២៩៦ ប្រក.កសក.មសរ/០៩ មិថុនា ១៩៩២/

**ប្រកាសស្តីពី ការអនុញ្ញាតអោយ ជំនាញសុរិយោដីប្រើប្រាស់លិខិតសញ្ញាពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ**

រដ្ឋមន្ត្រីក្រសួងកសិកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ ក្រច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃ ការធ្វើច្បាប់ និងបទបញ្ជា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៨៤ ស្តីពីតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- តាមសំណើរបស់នាយកដ្ឋានសុរិយោដី

សំរេច

មាត្រា១: អនុញ្ញាតអោយជំនាញសុរិយោដី ប្រើប្រាស់ជាផ្លូវការក្នុងទូទាំងប្រទេសនូវលិខិតសញ្ញាពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ មាន :

- លិខិតលក់ផ្តាច់
- លិខិតអំណោយផ្តាច់
- លិខិតចែកដី ក្នុងចំណែកដោយព្រមព្រៀងគ្នា ដែលក្រសួងកសិកម្មបានបោះពុម្ព និងលក់ចែកជូន ដូច មានឯកសារឧបសម្ព័ន្ធភ្ជាប់ជាមួយ ។

មាត្រា២: ជំនាញសុរិយោដីត្រូវមានភារកិច្ចអនុវត្តតាមគំរូលិខិតដូចមានចែងក្នុងមាត្រា១ខាងលើនេះ ។

មាត្រា៣: ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម

ងួន ញ៉ិល

Downloaded from http://www.khmerlaws.com